**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 21-Feb-2013, 14:24
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូងអំពីការលំបាកដែលនឹងអាចកើតមានឡើង ដោយសារតែការកម្រិតសក្ខីកម្មរបស់សាក្សី TCW-665 និង TCW-673 ត្រឹមតែការរៀបរាប់អំពីអត្តចរិតរបស់លោក ខៀវ សំផន

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

មេធាវី Jacques VERGÈS

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូរ ឧត្តរា

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យ៉ា សុខន

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

កញ្ញា Shéhérazade BOUARFA

កញ្ញា Mathilde CHIFFERT

កញ្ញា អ៊ួច ស្រីផាត់

លោក Pierre TOUCHE

កញ្ញា Blandine ZELLER

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**ក្រុមមេធាវីការពារក្តីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ មេធាវីការពារក្តីលោក ខៀវ សំផន បានផ្តល់បញ្ជីឈ្មោះសាក្សីអនុលោមតាមដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការរបស់អង្គជំនុំជម្រះ[1] ហើយក្នុងចំណោមនោះ មានសាក្សី TCW-665 និង TCW-673[2]។ មេធាវីការពារក្តីបានបញ្ជាក់ថា បុគ្គលទាំងពីររូបនេះជាសាក្សីដែលនឹងផ្តល់សក្ខីកម្មអំពីអង្គហេតុផង និងអត្តចរិតផង ហើយក៏បានលើកឡើងអំពីចំណុចនេះជាថ្មីម្តងទៀត កាលពីខែ កក្កដា ឆ្នាំ ២០១១[3]។

២. នៅខែ សីហា ឆ្នាំ ២០១២ ក្នុងឱកាសកិច្ចប្រជុំរៀបចំសវនាការ អង្គជំនុំជម្រះបានស្នើសុំជាអាទិ៍ឲ្យមេធាវីការពារក្តីទាំងអស់ផ្តល់សេចក្តីបញ្ជាក់បន្ថែមអំពីសំណើសុំកោះហៅសាក្សីរបស់ខ្លួន។

៣. ម្យ៉ាង អង្គជំនុំជម្រះបានស្នើសុំឲ្យមេធាវីការពារក្តីបញ្ជាក់អំពីបុគ្គលដែលមិនទាន់បានកោះហៅមកផ្តល់សក្ខីកម្ម ដែលមេធាវីការពារក្តីយល់ឃើញថាជា *"សាក្សីសំខាន់ដើម្បីបដិសេធការចោទប្រកាន់មកលើជនជាប់ចោទ"*[4]។

៤. ម្យ៉ាងទៀត អង្គជំនុំជម្រះបានស្នើសុំឲ្យមេធាវីការពារក្តីកំណត់អត្តសញ្ញាណសាក្សីណាខ្លះ ដែលខ្លួនមានបំណងចង់ឲ្យអង្គជំនុំជម្រះកោះហៅមកផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់ជនជាប់ចោទ ដោយ

---

[1] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9។

[2] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ (រួមនឹងឧបសម្ព័ន្ធ) ចុះថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/6 ឧបសម្ព័ន្ធ ១ ឯកសារ E9/4/6.2 ទំព័រ ៩ លេខរៀង ២៤ និង ២៥។

[3] សេចក្តីបញ្ជាក់អំពីសាក្សី និងអ្នកជំនាញដែលបានស្នើឡើង ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/11 ឧបសម្ព័ន្ធ ១ ឯកសារ E9/11.2 ទំព័រ ១១-១២ លេខរៀង ២៤ និង ២៥។ សំណើសុំដាក់បន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្នសម្រាប់ដំណាក់កាលដំបូងៗនៃការជំនុំជម្រះ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E93/8 ឧបសម្ព័ន្ធ ២ ឯកសារ E93/8.2 ទំព័រ ៣-៤ លេខរៀង ៧ និងទំព័រ ៤-៥ លេខរៀង ៩។

[4] អនុស្សរណៈស្តីពីការកំណត់កាលបរិច្ឆេទនៃកិច្ចប្រជុំរៀបចំសវនាការ ដើម្បីជួយដល់ការធ្វើផែនការសម្រាប់ដំណាក់កាលនៃការជំនុំជម្រះដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០១ និងការអនុវត្តវិធានការបន្ថែមដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃសវនាការ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E218 កថាខណ្ឌ ១២។

អង្គជំនុំជម្រះគ្រោងនឹងស្ដាប់សក្ខីកម្មរបស់សាក្សីទាំងនេះ *"នៅពេលបញ្ចប់ការពិភាក្សាដេញដោលលើអង្គសេចក្ដី"*[5]។

៥. មេធាវីការពារក្ដីលោក ខៀវ សំផន បានឆ្លើយតបទៅនឹងការស្នើសុំទាំងនេះ ដោយបានផ្ដល់ឈ្មោះសាក្សីទាំងពីរប្រភេទនេះ ហើយក្នុងចំណោមនោះ មានសាក្សី TCW-665 និង TCW-673។ នៅពេលនោះ មេធាវីការពារក្ដីលោក ខៀវ សំផន បានសង្កត់ធ្ងន់ថា បុគ្គលទាំងពីររូបនេះជាសាក្សីដែលនឹងមកផ្ដល់សក្ខីកម្មអំពីអង្គហេតុផង និងអត្តចរិតផង[6]។

៦. នៅថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីអំពីចេតនាកោះហៅសាក្សីអំពីអត្តចរិត ដែលស្នើដោយមេធាវីការពារក្ដី ឱ្យបានឆាប់ជាងការគ្រោងទុក។ ក្នុងគោលដៅនេះ អង្គជំនុំជម្រះបានរាយឈ្មោះសាក្សីប្រាំនាក់ដែលស្នើដោយលោក ខៀវ សំផន ហើយ បានស្នើសុំឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ *"ជូនដំណឹងមកអង្គជំនុំជម្រះ និងភាគី អំពីកាលបរិច្ឆេទដែលសាក្សីទាំងប្រាំរូប ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់ជនជាប់ចោទ អាចត្រូវបាននាំមកកាន់រាជធានីភ្នំពេញ ឬមួយក៏ស្ដាប់សក្ខីកម្មតាមប្រព័ន្ធសោតទស្សន៍ ដើម្បីអង្គជំនុំជម្រះអាចកំណត់កាលបរិច្ឆេទនៃការស្ដាប់សក្ខីកម្មពួកគាត់ នាពេលដ៏ខ្លីខាងមុខ"*[7]។

៧. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះដែលកំពុងប្រព្រឹត្តទៅ[8]។

---

[5] ដូចយោងខាងលើ កថាខណ្ឌ ១៧។

[6] បុគ្គលនានាដែលភាគីស្នើសុំមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម) ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E236 កថាខណ្ឌ ៥ និងកថាខណ្ឌ ៨។ សូមមើលផងដែរ៖ ប្រតិចារឹកសវនាការអសាធារណៈ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ទំព័រ ៦៩ បន្ទាត់ទី ២៥ និងទំព័រ ៧០ បន្ទាត់ទី ១-៥។

[7] អនុស្សរណៈស្ដីពីសេចក្ដីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនៃសវនាការ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E236/5 កថាខណ្ឌ ៣ [ជូនដំណឹងជាភាសាបារាំង នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៣]។

[8] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីវិសាលភាពនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13 ("សេចក្ដីសម្រេចរបស់អង្គជំនុំ

៨. នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ តាមរយៈអ៊ីមែលរបស់មន្ត្រីច្បាប់ជាន់ខ្ពស់ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា សវនាការពាក់ព័ន្ធនឹងផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលគ្រោងធ្វើជាដំបូង នៅថ្ងៃទី ១៤ និងថ្ងៃទី ១៥ ខែ កុម្ភៈ ត្រូវលើកទៅធ្វើនៅថ្ងៃទី ១៨ និងថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ វិញ ហើយការស្តាប់សក្ខីកម្មអ្នកជំនាញ TCE-80 ដែលគ្រោងជាដំបូងនៅសប្តាហ៍ចាប់ពីថ្ងៃទី ១៨ ខែ កុម្ភៈ ត្រូវបានលើកពេលទៅថ្ងៃក្រោយវិញ[9]។

៩. នៅល្ងាចថ្ងៃដដែលនោះ ការិយាល័យក្រឡាបញ្ជីបានផ្ញើអ៊ីមែលជូនដំណឹងដល់ភាគីថា សាក្សីអំពីអត្តចរិតទាំងពីររូប ដែលស្នើដោយលោក ខៀវ សំផន គឺសាក្សី TCW-665 និង TCW-673 នឹងត្រូវស្តាប់សក្ខីកម្ម ចាប់ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ តទៅ[10]។

១០. លិខិតឆ្លើយឆ្លងគ្នាថ្មីៗនេះរវាងអង្គជំនុំជម្រះសាលាដំបូង និងភាគី ស្តែងឲ្យឃើញថា សក្ខីកម្មរបស់សាក្សីទាំងពីររូបនេះនឹងកម្រិតត្រឹមតែការរៀបរាប់អំពីអត្តចរិតរបស់លោក ខៀវ សំផន ប៉ុណ្ណោះ។

១១. មេធាវីការពារក្តីសូមរំឭកដល់អង្គជំនុំជម្រះថា ក្រៅពីអាចផ្តល់សក្ខីកម្មអំពីអត្តចរិតរបស់លោក ខៀវ សំផន សាក្សី TCW-665 និង TCW-673 ក៏អាចផ្តល់សក្ខីកម្មអំពីអង្គហេតុផងដែរ។ ដូចបានលើកឡើងខាងលើ មេធាវីការពារក្តីបានជម្រាបជូនអង្គជំនុំជម្រះ តាំងពីខែ កុម្ភៈ ឆ្នាំ ២០១១ និងបានបញ្ជាក់ជាថ្មីម្តងទៀត កាលពីខែ កក្កដា ឆ្នាំ ២០១១ ហើយក៏បានសង្កត់ធ្ងន់អំពីចំណុចនេះទៀត នៅខែ សីហា និងខែ កញ្ញា ឆ្នាំ ២០១២[11]។

---

ជម្រះតុលាការកំពូល")។

[9] អ៊ីមែលរបស់លោកស្រី Susan LAMB ផ្ញើជូនភាគី នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ២ និង ៤៤ នាទីរសៀល មានចំណងជើង "*ការលើកពេល និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងបែបបទនៃសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងបញ្ហាពាក់ព័ន្ធ*"។

[10] អ៊ីមែលរបស់លោក Roger PHILLIPS ផ្ញើជូនភាគី នៅថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ វេលាម៉ោង ៤ និង ២៩ នាទីរសៀល មានចំណងជើង "*ផ្ញើបន្ត៖ ការលើកពេល និងព័ត៌មានផ្សេងទៀតពាក់ព័ន្ធនឹងបែបបទនៃសវនាការស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងបញ្ហាពាក់ព័ន្ធ*"។

[11] សេចក្តីបញ្ជាក់អំពីសាក្សី និងអ្នកជំនាញដែលបានស្នើឡើង ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/11 ឧបសម្ព័ន្ធ ១ ឯកសារ E9/11.2 ទំព័រ ១១-១២ លេខរៀង ២៤ និង ២៥។ សំណើសុំដាក់បន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្ន

១២. ជាក់ស្តែង សាក្សី TCW-673 បានរស់នៅជាមួយលោក ខៀវ សំផន តាំងពីដើមទសវត្សរ៍ឆ្នាំ៧០ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្រោយឆ្នាំ ១៩៧៩ រហូតដល់សព្វថ្ងៃ។ ច្បាស់ណាស់ថា សាក្សីរូបនេះពិតជាអាចត្រូវបានចោទសួរអំពីអ្វីដែលគាត់បានសង្កេតឃើញ ក្នុងរយៈកាលផ្សេងៗ ហើយសម្រង់នៃសក្ខីកម្មរបស់គាត់អាចដូចគ្នាទៅនឹងសក្ខីកម្មអំពីអង្គហេតុ។ ក្នុងបរិបទបែបនេះ ការជំទាស់ជាច្រើនអំពីប្រធានបទនៃការចោទសួររបស់ភាគីនានា ទំនងជាជៀសមិនផុតនោះទេ។

១៣. សាក្សី TCW-665 ធ្លាប់ធ្វើការនៅមន្ទីរក-១ និងមន្ទីរក-៣ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយបានទាក់ទងយ៉ាងជិតស្និទ្ធជាមួយលោក ខៀវ សំផន នៅក្រោយឆ្នាំ ១៩៧៩។ ដូច្នេះ សក្ខីកម្មរបស់សាក្សីរូបនេះក៏អាចលាតសន្ធឹងទៅដល់អង្គហេតុផងដែរ។

១៤. អាស្រ័យហេតុនេះ ទាំងចំពោះសាក្សី TCW-665 និងសាក្សី TCW-673 ទិដ្ឋភាពអង្គហេតុ និងអត្តចរិតហាក់ដូចជាមានភាពជាប់ទាក់ទងគ្នាមិនអាចកាត់ផ្តាច់បាន ហើយការកម្រិតសក្ខីកម្មរបស់ពួកគាត់ត្រឹមតែការរៀបរាប់យ៉ាងសាមញ្ញអំពីអត្តចរិត ដែលងាកចេញពីបរិបទអង្គហេតុនៃការសង្កេតឃើញអត្តចរិតនេះ អាចធ្វើឲ្យស្រងាកចិត្តយ៉ាងខ្លាំង។

១៥. តាមធម្មតា មេធាវីការពារក្តីលោក ខៀវ សំផន គួរតែស្នើសុំជាថ្មីម្តងទៀតថា សាក្សីទាំងពីររូបនេះ អាចត្រូវបានស្តាប់ចម្លើយអំពីអង្គហេតុផងដែរ ដោយគូសបញ្ជាក់ថា គ្មានភាគីណាមួយធ្លាប់ជំទាស់ទៅនឹងការផ្តល់សក្ខីកម្មរបស់សាក្សីទាំងនេះអំពីអង្គហេតុ និង/ឬអត្តចរិតនោះទេ។ ក៏ប៉ុន្តែ សំណើបែបនេះនឹងមិនទទួលបានជោគជ័យនោះទេ នាពេលឥឡូវនេះ។

---

សម្រាប់ដំណាក់កាលដំបូងៗនៃការជំនុំជម្រះ ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារ E93/8 ឧបសម្ព័ន្ធ ២ ឯកសារ E93/8.2 ទំព័រ ៣-៤ លេខរៀង ៧ និងទំព័រ ៤-៥ លេខរៀង ៩។ ប្រតិចារឹកសវនាការអសាធារណៈ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ ឯកសារ E1/114.1 ទំព័រ ៦៩ បន្ទាត់ទី២៥ និងទំព័រ ៧០ បន្ទាត់ទី១-៥។ បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម) ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២ ឯកសារ E236 កថាខណ្ឌ ៥ និងកថាខណ្ឌ ៨។

១៦. ជាការពិត សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបង្កឱ្យមានភាពមិនច្បាស់លាស់លើវិសាលភាពនៃសំណុំរឿងកំពុងជំនុំជម្រះនេះ (និងលើវិសាលភាពនៃសក្ខីកម្មរបស់សាក្សីផងដែរ) រហូតទាល់តែអង្គជំនុំជម្រះសាលាដំបូងសម្រេចបញ្ហានេះជាថ្មីម្តងទៀត។

១៧. ក្នុងល័ក្ខខ័ណ្ឌនេះ ការស្តាប់សក្ខីកម្មសាក្សី TCW-665 និង TCW-673 ចាប់ពីថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១៣ហាក់ដូចជាឆាប់ពេក។ មេធាវីការពារក្តីមិនយល់សោះថា ហេតុអ្វីបានជាអង្គជំនុំជម្រះត្រូវប៉ុនប៉ងបេសកកម្មមិនអាចទៅរួច ក្នុងការបំបែកទិដ្ឋភាពអង្គហេតុ ចេញពី "អត្តចរិត" ដើម្បីឱ្យតែសវនាការអាចប្រព្រឹត្តទៅបាន បើទោះជាមានភាពយឺតយ៉ាវផ្សេងៗរួចមកហើយ និងដើម្បីឱ្យតែការជំនុំជម្រះក្តីមានភាពឆាប់រហ័ស។

១៨. មេធាវីការពារក្តីលោក ខៀវ សំផន សូមលើកឡើងយ៉ាងទទូចថា សិទ្ធិរបស់មេធាវីការពារក្តីទាំងមូលមិនត្រូវទទួលរងការរំលោភបំពាន ដោយសារតែការចង់បន្តសវនាការ *"ឱ្យតែមានថ្ងៃទំនេរ"*[12] នោះទេ។

១៩. **អាស្រ័យហេតុនេះ** មេធាវីការពារក្តីលោក ខៀវ សំផន ស្នើសុំអង្គជំនុំជម្រះសាលាដំបូងមេត្តាផ្អាកការកោះហៅសាក្សី TCW-665 និង TCW-673 សិន ដោយរង់ចាំការសម្រេចជាថ្មីពីអង្គជំនុំជម្រះសាលាដំបូង អនុលោមតាមសេចក្តីសម្រេចថ្មីៗនេះរបស់អង្គជំនុំជម្រះតុលាការកំពូល។

---

[12] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៥១៖ *"ជាការតម្រូវថា អ.វ.ត.ក ដំណើរការជារៀងរាល់ថ្ងៃដែលខ្លួនអាចធ្វើទៅបាន ដើម្បីធានាបាននូវការសម្រេចជាស្ថាពរលើបទចោទដែលសេសសល់ឱ្យបានឆាប់ដែលអាចធ្វើទៅបាន"* ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងយោងដល់ ដើម្បីបញ្ជាក់មូលហេតុនៃការបើកសវនាការភ្លាមៗពាក់ព័ន្ធនឹងផលវិបាកនៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល៖ *សេចក្តីណែនាំដល់ភាគីនានា ដោយសារតែមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ (ឯកសារ E163/5/1/13)* អនុស្សរណៈ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ E163/5/1/13/1 កថាខណ្ឌ ៣ កំណត់សម្គាល់ជើងទំព័រ ២ [ជូនដំណឹងជាផ្លូវការដល់ភាគី ជាភាសាអង់គ្លេស និងភាសាខ្មែរ នៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៣]។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN<br><br>មេធាវី Jacques VERGÈS | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស<br><br>ទីក្រុងប៉ារីស | *[ហត្ថលេខា]*<br><br>*[ហត្ថលេខា]*<br><br>*[ហត្ថលេខា]*<br><br>*[ហត្ថលេខា]* |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |